ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣០/១១-ឌីកនើធី នីតធើរ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: ម៉ារ សំបូរណា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: ទូន ស៊ីផាន់
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: ប៉ែន ប៊ុនឈា

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ឌីកនើធី នីតធើរ លីមីធីត**
អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៦ ៧០៦ ១៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក តាំង ស៊ុនហេង | រដ្ឋបាល |
| ២- លោក Zhong Hai | Production Manager |
| ៣- លោក Jiang Wei | P.M Assistant |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**
- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ឌីកនើធី នីតធើរ**

អាសយដ្ឋាន ៖ ភូមិព្រែកតាព្រីង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៦ ២៣៥ ៤៥៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោក សាន សុផា — មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា
២- លោក ភិន សុភា — ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ
៣- លោក ចឹក ប៊ុនសាន — អនុប្រធានសហជីព
៤- លោក សេង សឿង — លេខាធិការសហជីព
៥- កញ្ញា ព្រហ្ម សោភា — សកម្មជនសហជីព
៦- កញ្ញា ចេង ស្រីទូច — សកម្មជនសហជីព
៧- កញ្ញា ទែន សាម៉េន — សកម្មជនសហជីព
៨- កញ្ញា ម៉ុក ណារី — សកម្មជនសហជីព
៩- កញ្ញា យស់ ថារី — សកម្មជនសហជីព
១០- កញ្ញា ម៉ន ស្រីមុំ — សកម្មជនសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ស្នើឱ្យក្រុមហ៊ុនតម្លើងតម្លៃឡូតិ៍ ដូចខាងក្រោមៈ

- ផ្នែកម៉ុកព្រុយ PN (9047-9048) សូមតម្លើងឱ្យបាន ០.៩៥ ដុល្លា ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូមផ្តល់ជូន ០.៨៥ ដុល្លា ។
- ផ្នែកដេរ PN (9047-9048) សូមតម្លើងឱ្យបាន ១.២ ដុល្លា ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូមផ្តល់ជូន ០.៨៩ ដុល្លា ។
- ផ្នែកផុងខ្លួន PN (975525) សូមតម្លើងឱ្យបាន ១.៦៥ ដុល្លា ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូមផ្តល់ជូន ១.៥៥ ដុល្លា ។
- PN (10051) សូមតម្លើងឱ្យបាន ០.៣ ដុល្លា ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូម ផ្តល់ជូន ០.២៥ ដុល្លា
- ផ្នែកផុងក PN (9047-9048) សូមតម្លើងឱ្យបាន ០.៨ ដុល្លា ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសូមផ្តល់ជូន ០.៧៨ ដុល្លា ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៦៧/១១ កប/កណ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

**សវនាការ និង សង្ខេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានប្រជុំដោះស្រាយវិវាទការងាររួមចំនួន០១ចំណុច ដោយមិនទទួលបានលទ្ធផលមិនសះជានឹងទេ។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៤៦៧/១១ កប/កណ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាលើចំណុចវិវាទទាំងទងនឹងតម្លៃឡូត៍នៅផ្នែកដេរ (PN ៩០៤៧-៩០៤៨) និងផ្នែកផុងក (PN ៩០៤៧-៩០៤៨)។ ចំណែកឯចំណុចនៅសល់ គឺទាក់ទងនឹង PN នៅផ្នែកម៉ុកព្រុយ (PN ៩០៤៧-៩០៤៨) នៅផ្នែកផុងខ្លួន(PN ៩៧៥៥២៥) និង PN ១០០៥១ ។

នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានឯកភាពជ្រើសរើសយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ភាគីនិយោជក និងភាគីសហជីព ព្រមព្រៀងគ្នាក្នុងការពន្យាថ្ងៃចេញសេចក្តីបង្គាប់រហូតដល់ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១១។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ឌីកនើធី នីតធើរ ជូនលោក តាំង ស៊ុនហេង និង លោក Zhong Hai ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ។

២- លិខិតរបស់របស់ក្រសួងពាណិជ្ជកម្មលេខ ៤៩៦៤ ពណ.ចបព ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ជម្រាបមកលោកអភិបាលក្រុមហ៊ុន ឌីកនើធី នីតធើរ ស្តីពីករណីសុំចុះបញ្ជីតម្កល់ទុកការទិញ (ACQUISI-TION) ភាពជាម្ចាស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ក្រុមហ៊ុន ។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះខែមិថុនា ឆ្នាំ ២០១១ ។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វីវើរ រិច ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ។

៥- លក្ខន្តិកៈក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ។

៦- សៀវភៅកត់ឡូតិ៍ផ្នែក មុំក និង ដេរ ។

៧- តារាងប្រាក់ឈ្នួលប្រចាំខែ ០៩ ឆ្នាំ២០១១ ។

៨- អត្តលេខរបស់កម្មករផ្នែកដេរក នៃផ្នែកផុងភ្ជាប់ចំនួន១២០នាក់ ។

៩- អត្តលេខរបស់កម្មករផ្នែកដេរខ្លួន នៃផ្នែកផុងភ្ជាប់ចំនួន១៣២នាក់ ។

១០- អត្តលេខរបស់កម្មករផ្នែកដេរ នៃផ្នែកកាត់ព្រុយចំនួន ៥៦នាក់ ។

១១- អត្តលេខរបស់កម្មករផ្នែកមុំក នៃផ្នែកកាត់ព្រុយចំនួន៥០នាក់ ។

១២- កាតការងារ ដែលមានលេខកាត ZQ3023 ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឌីកនើធី នីតធើរ លេខ ៤៦៧/១១ កប/កណ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឌីកនើធី នីតធើរ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៧២៩ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧៣០ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។

៣-ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទទាំងអស់ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ឌីកនើធី នីតធើរ ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅខែមិថុនា ឆ្នាំ២០១១។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុន ចាក់ ប៉ាក់ បោះពុម្ពសំលៀកបំពាក់ ស្រោមជើង ស្រោមដៃ និងកន្សែងបង់ក ហើយមានជួលកម្មករនិយោជិតសរុបចំនួន ១៩១៨ នាក់។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ (ស៊ីខៅឌូ) ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះមានសមាជិកចំនួន ១៩០០ នាក់។

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨) និង ផ្នែកផុងខ្លួន PN (៩៧៥៥២៥) និង PN (១០០៥១)

- ម៉ោងការងាររបស់កម្មករនិយោជិត គឺចាប់ផ្តើមធ្វើការពីម៉ោង ៧ និង ០០ នាទី ទៅដល់ម៉ោង ១១ និង ០០ នាទី ព្រឹក។ ពេលរសៀល ចាប់ផ្តើមចូលពីម៉ោង ១២ និង ៣០ នាទី ដល់ម៉ោង ៤ និង ៣០ នាទី ល្ងាច។ ជាទូទៅនិយោជកតែងតែមានការងារថែមម៉ោងដោយបន្តពីម៉ោង ៤ និង ៣០ នាទី រហូតដល់ម៉ោង ០៦ និង ៣០ នាទី ល្ងាច។
- ភាគីនិយោជកបញ្ជាក់ថា និយោជកពុំបានឱ្យកម្មករនិយោជិតដេរសាកល្បងទេ ចំពោះការកំណត់តម្លៃឡូតិ៍កន្លងមក។ ក្រុមហ៊ុនកំណត់ចេញតម្លៃឡូតិ៍នៅថ្ងៃទី២៥ នៃខែនីមួយៗ។
- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨) ដល់ចំនួន ០,៩៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និងផ្នែកផុងខ្លួន PN (៩៧៥៥២៥) ដល់ចំនួន ១,៦៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង PN (១០០៥១) ដល់ចំនួន ០,៣ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។
- ភាគីនិយោជកអាចតម្លើងតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨) ដល់ចំនួន ០,៨៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង ផ្នែកផុងខ្លួន PN (៩៧៥៥២៥) ដល់ចំនួន ១,៥៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង PN (១០០៥១) ដល់ចំនួន ០,២៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ចំពោះ PN ផ្នែកម៉ុកព្រុយ PN ផ្នែកផុងខ្លួនខាងលើនេះ គឺកម្មករនិយោជិតបានចាប់ផ្តើមធ្វើ (ដេរ) ពីខែកញ្ញា រហូតដល់ដើមខែតុលា ឆ្នាំ២០១១។ ពោលគឺបានធ្វើរួចរាល់អស់ហើយ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់ទាមទារនេះ គឺសម្រាប់តែ PN ផ្នែកម៉ុកព្រុយ PN ផ្នែកផុងខ្លួនដែលបានធ្វើហើយនេះប៉ុណ្ណោះ គឺមិនទាមទារសម្រាប់ PN ទាំងនេះទៅថ្ងៃខាងមុខទៀតទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា មូលហេតុដែលពួកគាត់ទាមទារនេះ គឺដោយសារតែក្រុមហ៊ុនទំលាក់

តម្លៃឡូតិ៍ទាបជាងមុន ជាក់ស្តែងដូចជា ពីមុនផ្នែកម៉ុកព្រុយ PN (៤០៨៥) ដែលងាយស្រួលធ្វើជាង ឬប្រហាក់ប្រហែលគ្នាជាមួយនឹង PN (៩០៤៧-៩០៤៨) នេះ ក្រុមហ៊ុនផ្តល់ជូន ០,៩៣ ដុល្លារអាមេរិ ក្នុងមួយឡូតិ៍។ ប៉ុន្តែ នៅពេលក្រុមហ៊ុនចេញតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨ )នេះ គឺត្រឹមតែ ០,៨៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ចំណែកឯ PN ផុងខ្លួន (៩៧៥៥២៥) គឺស្រដៀងគ្នា ឬងាយស្រួលធ្វើជាង PN ផុងខ្លួន ចាស់ (៩៧៥៥២៦) ហើយក្រុមហ៊ុនបានផ្តល់ជូន ១,៦៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ តែ PN ផុងខ្លួន (៩៧៥៥២៥) នេះ ក្រុមហ៊ុនផ្តល់ជូនតែ ១,៥៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ ទៅវិញ។
- ភាគីនិយោជកបញ្ជាក់ថា PN នីមួយៗ មានម៉ូតខុសៗគ្នា ជាក់ស្តែងដូចជា PN ផុងខ្លួន (៩៧៥៥២៥) ដែលកម្មករនិយោជិតលើកឡើង គឺខុសគ្នាពី PN ផុងខ្លួន (៩៧៥៥២៦) ដោយសារមានម៉ូត និងការដេរខុសគ្នា ហើយសំរុងក៏ខ្លីជាងមុនដែរ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ចំពោះ PN (១០០៥១) គឺមានការពិបាកជាង PN ចាស់ (៣០០៧) ដែលពេលនោះ ក្រុមហ៊ុនផ្តល់ជូនដល់ទៅ ០,៣ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។
- ភាគីនិយោជកបានបញ្ជាក់ថា បើប្រៀបធៀបតម្លៃឡូតិ៍ដែលកម្មករនិយោជិតលើកឡើងនេះ គឺតម្លៃឡូតិ៍ទាបជាងគ្នាបន្តិចមែន។ ប៉ុន្តែ ក្រុមហ៊ុនពិនិត្យឃើញថា តម្លៃឡូតិ៍ដែលក្រុមហ៊ុនផ្តល់ជូននេះ កម្មករនិយោជិតធ្វើ(ដេរ)បានលើសពីប្រាក់ឈ្នួលគោលហើយ ដូចមានបញ្ជាក់ក្នុងតារាងបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងខែកញ្ញា ឆ្នាំ២០១១ ដែលភាគីនិយោជកបានផ្តល់មកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីគាំទ្រការលើកឡើងរបស់ខ្លួន។ ភាគីកម្មករនិយោជិតមិនជំទាស់ទៅនឹងការលើកឡើងនេះទេ។
- ភាគីនិយោជកបញ្ជាក់ថា មានកម្មករនិយោជិតភាគច្រើន ដែលដេរបានលើសប្រាក់ឈ្នួលគោលក្នុងរយៈពេល ៨ ម៉ោង នៃម៉ោងធ្វើការធម្មតា។ នៅពេលដែលកម្មករនិយោជិតណា ដេរមិនគ្រប់ប្រាក់ឈ្នួលគោល គឺនិយោជកបន្ថែមឱ្យបានគ្រប់ប្រាក់ឈ្នួលគោល។ ភាគីនិយោជកបន្តថា យោងតាមតារាងបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតនៅក្នុងខែកញ្ញា ឆ្នាំ២០១១ ភាគច្រើនកម្មករនិយោជិតដែលដេរមិនបានគ្រប់ប្រាក់ឈ្នួលគោលនោះ គឺកម្មករនិយោជិតមិនបានមកធ្វើការគ្រប់ចំនួន ២៦ថ្ងៃ នៃថ្ងៃធ្វើការធម្មតាទេ។
- ភាគីនិយោជកបញ្ជាក់ថា ចំពោះខែកញ្ញា នេះ គឺមានការឈប់សម្រាកថ្ងៃបុណ្យច្រើន ដូចនេះកម្មករនិយោជិត ដែលបានមកធ្វើការចំនួន ២០ ថ្ងៃ ចាត់ទុកថា បានធ្វើការគ្រប់ចំនួនថ្ងៃធ្វើការធម្មតាហើយ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨) និង ផ្នែកផុងខ្លួន PN (៩៧៥៥២៥) និង PN (១០០៥១)

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ? ⌇

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬ អនុសញ្ញារូមណាមួយចែងពីការទាមទារនោះ "* ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *០៥/១១-អ៊ីម វើ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ប្លូលកាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។ ការទាមទារក្នុងចំណុចនេះ គឺទាក់ទងនឹងអត្រាប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតតាមបរិមាណផលិតផល ហេតុនេះចំណុចវិវាទនេះជាចំណុចវិវាទអំពីសិទ្ធិ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម៖

មាត្រា ១០៨ នៃច្បាប់ស្តីពីការងារចែងថា *"ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ទោះធ្វើនៅរោងជាង ឬនៅលំនៅក៏ដោយ ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិត ដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតាបានទទួលក្នុងចិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិត "* ។

ចំណុចទី ២ និងចំណុចទី ៣ នៃសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០១០ ចែងថា ២. *"កំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងចំនួន ៥៦ (ហាសិបប្រាំមួយ) ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតសាកល្បងពី ១ខែ ទៅ ៣ខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៤៥ ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើ ៥៦ដុល្លារ)* ។ *ចប់រយៈពេលសាកល្បង កម្មករនិយោជិតពេញសិទ្ធិត្រូវទទួលប្រាក់ឈ្នួលអប្បបរមាចំនួន៦១ (ហុកសិបមួយ) ដុល្លារអាមេរិក ក្នុងមួយខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៥០ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើ៦១ ដុល្លារ)* ។ *៣. ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីប៉ុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន* ។ *បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួលដែលមានចែងក្នុងចំណុចទី២ ខាងលើ ត្រូវទទួលបានតាមការលើសនោះ* ។ *ប្រសិនបើទាបជាង និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួន ៥៦ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន៦១ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ "* ។

នៅក្នុងសេចក្តីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា *"និយោជកមានសិទ្ធិកំណត់ ឬផ្លាស់ប្តូរតម្លៃប៉ុង ក៏ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចថា ត្រូវកំណត់ធ្វើយ៉ាងណា ឱ្យតម្លៃប៉ុងឱ្យកម្មករនិយោជិត ដែលមានការប៉ិនប្រសប់មធ្យម ធ្វើការធម្មតាអាចទទួលបានប្រាក់ឈ្នួលអប្បបរមា"* ។ (សូមមើលសំណុំរឿងលេខ *០៣/០៥-ហ្គាយអ៊ីង ដ្រាហ្គុង ចំណុចវិវាទទី៦, លេខ ៤១/០៥-វ៉ាយអូលែត ចំណុចវិវាទទី៨ និង លេខ ៤៤/០៦-ហ្គោលហ្វេម ចំណុចវិវាទទី១*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះក៏ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា តាមរយៈតារាងបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត

នៅក្នុងខែកញ្ញា ឆ្នាំ២០១១ បានបង្ហាញថា មានកម្មករនិយោជិតចំនួន ៣៥៤ នាក់ (៧៨%) នៃកម្មករនិយោជិតចំនួន ៤៥២ នាក់ ដែលធ្វើការក្នុងចិរវេលាធ្វើការធម្មតាទទួលបានប្រាក់ឈ្នួលលើសពីប្រាក់ឈ្នួលអប្បបរមា ដែលកំណត់ដោយសេចក្តីជូនដំណឹងលេខ ០៤៩/១០។ ប៉ុន្តែមានកម្មករនិយោជិតចំនួនតែ ៩៨ នាក់ (២២%) នៃកម្មករនិយោជិតចំនួន ៤៥២ នាក់ ដែលដេរមិនគ្រប់ប្រាក់ឈ្នួលអប្បបរមា ហើយភាគច្រើនកម្មករនិយោជិតទាំងនោះ មិនបានមកធ្វើការគ្រប់ចំនួនថ្ងៃធ្វើការធម្មតានោះទេ។ យោងតាមអង្គហេតុ ចំពោះកម្មករនិយោជិតដែលដេរមិនគ្រប់ប្រាក់ឈ្នួលអប្បបរមា គឺនិយោជកបានបង្គ្រប់ឱ្យដល់ប្រាក់ឈ្នួលអប្បបរមាហើយ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យនិយោជកតម្លើងតម្លៃឡូតិ៍ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨ ) ដល់ ០,៩៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និងផ្នែកផុងខ្លួន PN (៩៧៥៥២៥) ដល់ ១,៦៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង PN (១០០៥១) ដល់ ០,៣ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទ៖

បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកតម្លើងតម្លៃឡូតិ៍ ផ្នែកម៉ុកព្រុយ PN (៩០៤៧-៩០៤៨ ) ដល់ ០,៩៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង ផ្នែកផុងខ្លួន PN (៩៧៥៥២៥) ដល់ ១,៦៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ និង PN (១០០៥១) ដល់ ០,៣ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍។

ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយសារភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖

ឈ្មោះ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖

ឈ្មោះ៖ **នួន ស៊ីផាន់**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល៖

ឈ្មោះ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ----------------------------------------